**មាត្រា ២** : នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត អោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមានពុកប់ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ១៩៩៦

ក្នុងព្រះបរមនាម និងតាមព្រះរាជបង្គាប់

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា**

**ជា ស៊ីម**

* * *

**ព្រះរាជក្រឹត្យ នស/រកត/០៤៩៦/២៥**

**យើងព្រះបាទសម្តេចព្រះនរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស**

**ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម**

**ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុង**

**កម្ពុជាធិបតី**

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យ ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលជាតិកម្ពុជា
- តាមសេចក្តីស្នើរបស់សម្តេចនាយករដ្ឋមន្ត្រីទាំងពីរ :

**ទ្រង់ត្រាសសំរេច** :

**មាត្រា ១** : បង្កើតអាជ្ញាធរជាតិមួយសំរាប់ទទួលបន្ទុកដោះស្រាយកិច្ចការព្រំដែនហៅថា «អាជ្ញាធរ ជាតិទទួលបន្ទុកកិច្ចការព្រំដែន » ដែលមានសមាសភាពដូចតទៅ :

១-សម្តេចក្រុមព្រះ នាយករដ្ឋមន្ត្រីទី១

២–សម្តេច នាយករដ្ឋមន្ត្រីទី២ សហប្រធាន
៣–សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អនុប្រធាន
៤–រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ អនុប្រធាន
៥–ឯកឧត្តម ឌិត មុន្នី អតីតប្រធានគណៈកម្មាធិការព្រំដែន ទីប្រឹក្សាប្រចាំអាជ្ញាធរ
៦–សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក
៧–រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
៨–សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សមាជិក
៩–អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ សមាជិក
១០–ឯកឧត្តម វ៉ា គីមហុង ទីប្រឹក្សាសម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី១ និងសម្តេចនាយក រដ្ឋមន្ត្រីទី២ ទទួលបន្ទុកការងារព្រំដែនឋានៈស្មើរដ្ឋលេខាធិការ សមាជិកអចិន្ត្រៃយ៍
១១–ឯកឧត្តម ឡុង វិសាលោ ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រីទី២ សមាជិក
១២–ប្រធាននាយកដ្ឋានភូមិសាស្ត្រ អគ្គលេខាធិការ

**មាត្រា ២** : អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន មានភារកិច្ច ÷

– រៀបចំ និងកសាងលិខិតបទដ្ឋានមានលក្ខណៈច្បាប់ស្តីពីការកំណត់ព្រំដែនដីគោក និង ព្រំដែនសមុទ្រ ដើម្បីយកទៅតំកល់នៅទីស្នាក់ការអង្គការសហប្រជាជាតិ ។

–ស្រាវជ្រាវនិងសិក្សាអោយបានហ្មត់ចត់បំផុត ក្នុងការជ្រើសរើសយកផែនទីលំនាំណាមួយសំរាប់ធ្វើការកំណត់បន្ទាត់ព្រំដែនដីគោកនិងព្រំដែនសមុទ្រអោយបានច្បាស់លាស់ រវាងព្រះ រាជាណាចក្រកម្ពុជា ជាមួយបណ្តាប្រទេសជិតខាង ។

–ធ្វើការចរចា សំរបសំរួល ដោះស្រាយ និងសំរេចលើបញ្ហាព្រំដែនជាមួយបណ្តាប្រទេសជិតខាងលើរាល់កិច្ចការដែលមានទំនាក់ទំនងលើការងារព្រំដែន ក្រោយពីមានការឯកភាពពីគណៈរដ្ឋមន្ត្រី ។

–សហប្រធានមានសិទ្ធិចុះហត្ថលេខាលើសន្ធិសញ្ញាស្តីពីបញ្ហាព្រំដែន ក្នុងនាមអាជ្ញាធរទទួលបន្ទុកកិច្ចការព្រំដែន ។

**មាត្រា ៣** : អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន មានយន្តការ ២ ជាលេខាធិការ :

**យន្តការទី១** :ជាគណៈកម្មាធិការនីតិកម្មស្តីពីកិច្ចការព្រំដែន(Task Force sur létude juridique)សមាសភាពនិងភារកិច្ចនៃគណៈកម្មាធិការនេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**យន្តការទី២**:ជាគណៈកម្មាធិការបច្ចេកទេសស្តីពីកិច្ចការព្រំដែន ( Task Force Technique) ។ សមាសភាពនិងភារកិច្ចនៃគណៈកម្មាធិការនេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៤** : យន្តការទាំងពីរនេះមានលេខាធិការដ្ឋានរួមមួយអចិន្ត្រៃយ៍ នៅនាយកដ្ឋានភូមិសាស្ត្រនៃទីស្តីការគណៈរដ្ឋមន្ត្រី ហៅថា : លេខាធិការដ្ឋានអចិន្ត្រៃយ៍នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែនដែលមាន ÷

-ឯកឧត្តម **វ៉ា គឹមហុង** ជាសមាជិកអចិន្ត្រៃយ៍អាជ្ញាធរទទួលបន្ទុកលេខាធិការដ្ឋាន

-ឯកឧត្តម **ម្ចាស់ លាស់** ជាជំនួយការទទួលបន្ទុកលេខាធិការដ្ឋាន

-ប្រធាននាយកដ្ឋានភូមិសាស្ត្រ អគ្គលេខាធិការអាជ្ញាធរ ជាប្រធានលេខាធិការដ្ឋាន

-ប្រធាននាយកដ្ឋានស្វ័យោជី អនុប្រធានលេខាធិការដ្ឋាន

-លេខាធិការនៃគណៈកម្មាធិការនីតិកម្ម ស្តីពីកិច្ចការព្រំដែន ជាសមាជិក

-លេខាធិការនៃគណៈកម្មាធិការបច្ចេកទេស ស្តីពីកិច្ចការព្រំដែន ជាសមាជិក

-មន្ត្រីជំនាញការមួយចំនួន តាមសេចក្តីត្រូវការជាក់ស្តែង

លេខាធិការដ្ឋាននេះ ជាអ្នកសំរបសំរួលកិច្ចការ រវាងគណៈកម្មាធិការនីតិកម្មស្តីពីកិច្ចការព្រំដែន និងគណៈកម្មាធិការបច្ចេកទេសស្តីពីកិច្ចការព្រំដែន ហើយជាក្បាលម៉ាស៊ីនរដ្ឋបាល និងជាហិរញ្ញកិច្ចរបស់អាជ្ញាធរ ជាតិទទួលបន្ទុកកិច្ចការព្រំដែន ដោយប្រើប្រាស់មន្ត្រីរបស់នាយកដ្ឋានភូមិសាស្ត្រ នាយកដ្ឋានស្វ័យោជី មន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ និងមន្ត្រីនៃលេខាធិការដ្ឋានរបស់យន្តការទាំង២ សំរាប់ជំនួយការ ។ លេខាធិការដ្ឋាន អចិន្ត្រៃយ៍នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន មានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

លេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ទទួលបន្ទុកកសាងផែនការ ចំណាយរបស់អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ។

**មាត្រា ៥** : លេខាធិការដ្ឋាន មានភារកិច្ច ÷

-សិក្សាស្រាវជ្រាវនិងស្វែងយល់បន្ថែមលើការងារបច្ចេកទេស ដែលពាក់ព័ន្ធទៅ នឹងបញ្ហាព្រំដែនដើម្បីរៀបចំ និង កសាងដោយផ្ទាល់អោយបានលិខិតបទដ្ឋានមានលក្ខណៈច្បាប់ សំរាប់យកទៅដាក់ជូនអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ។

-ចុះពិនិត្យនិងធ្វើការវាស់វែងដល់ទីកន្លែងកើតហេតុនានាតាមបណ្តោយព្រំដែន រួចរាយការណ៍ជូនអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ដើម្បីពិនិត្យ និង សំរេច ។

-ចូលរួមចរចាជាមួយប្រទេសជិតខាង ដើម្បីកំណត់ជ្រើសរើសយកផែនទីសំរាប់ធ្វើជាមូលដ្ឋានក្នុងការដោះស្រាយបញ្ហាបច្ចេកទេសអោយបានត្រឹមត្រូវច្បាស់លាស់ ។

-សហការជាមួយអភិបាល ឬ អភិបាលរងខេត្ត ក្រុងដែលនៅជាប់ព្រំដែនជាមួយប្រទេសជិតខាងក្នុងការសិក្សាស្រាវជ្រាវលើទីតាំងព្រំដែន សីមា ដាក់ស្លែងទៅនឹងបញ្ហាបច្ចេកទេសជំនាញ រួចរាយការណ៍អំពីលទ្ធផល ជូនអាជ្ញាធរទទួលបន្ទុកកិច្ចការព្រំដែន ។

-ធ្វើរបាយការណ៍តាមតំណាក់កាលនីមួយៗ អំពីសភាពការណ៍នៃការដោះស្រាយ និងការកំណត់ព្រំដែនជាមួយប្រទេសជិតខាង ជូនអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន សំរាប់រាយការណ៍ ថ្វាយនិងជូនគណៈរដ្ឋមន្ត្រី ។

**មាត្រា ៦** : អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន មានសិទ្ធិប្រើប្រាស់ត្រារបស់គណៈរដ្ឋមន្ត្រី សំរាប់សំរួលការងារ ។

សមាជិកអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់សហប្រធាន ។

**មាត្រា ៧** : អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែនមានខ្ទង់ថវិកាដោយឡែក សំរាប់ចំណាយដោយផ្ទាល់ក្នុងការងាររបស់ខ្លួន នៅទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា ៨** : សម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី១ សម្តេចនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលជាតិកម្ពុជា រដ្ឋមន្ត្រីពាក់ព័ន្ធ រដ្ឋមន្ត្រីនិងអគ្គភាពសាមី និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចព្រះរាជ ក្រឹត្យនេះ ។

**មាត្រា ៩** : ព្រះរាជក្រឹត្យនេះចូលជាធរមានច្បាប់ចាប់ពីថ្ងៃឡាយព្រះរាជហស្តលេខានេះតទៅ

ហើយ ជំនួសអោយព្រះរាជក្រឹត្យលេខ នសរកត ០២៩៥-១៩ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ដែលត្រូវទុកជានិរាករណ៍ ។

រាជធានីភ្នំពេញ , ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ១៩៩៦

ព្រះហស្តលេខា

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខានិងត្រា | ហត្ថលេខានិងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *